## សម្រង់សារព័ត៌មានថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧

### ១.គេហទំព័រ ដើមអម្ពិល

### *មន្ត្រី-បុគ្គលិក អាជ្ញាធរ ជាតិអប្សរាទទួលវគ្គបណ្តុះបណ្តាល អំពីវិទ្យាសាស្ត្រពាក់ព័ន្ធនឹងការអភិរក្ស បុរាណដ្ឋាននៅតំបន់អង្គរពីអ្នកជំនាញកូរ៉េ*

អង្គារ, ២៥ កក្កដា ២០១៧ 09:04 ដោយ: ដើមអម្ពិល ID:069



មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាចំនួន១០ នាក់នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យាន អង្គរនិងបុរាណវិទ្យាបង្ការ បានចូលរៀនវគ្គបណ្តុះបណ្តាលស្តីអំពីវិទ្យាសាស្ត្រពាក់ព័ន្ធនឹងការអភិរក្សបុរាណដ្ឋានក្នុងតំបន់អង្គរ ពីសំណាក់លោកបណ្ឌិត Chung Yongjae សាស្ត្រាចារ្យសាកលវិទ្យាល័យជាតិកូរ៉េនៃបេតិកភណ្ឌវប្បធម៌ នារសៀលថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧។

វគ្គសិក្សានេះមានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៤ដល់២៨ ខែកក្កដា ឆ្នាំ២០១៧ ដោយផ្តោតទៅលើការសិក្សាអំពីធាតុផ្សំនៃ ថ្មនៅតំបន់អង្គរ ការធ្វើតេស្តថ្ម ការសិក្សាអំពីមូលដ្ឋានវិទ្យាសាស្ត្រសម្រាប់ការងារអភិរក្ស ការពិសោធន៍និងវិភាគដោយ មាស៊ីនMicroscope ការសិក្សាអំពីសិលាវិទ្យា និងការចុះអនុវត្តលើទីតាំងផ្ទាល់។

តាមការបញ្ជាក់ពីលោកសាស្ត្រាចារ្យ Chung Yongjae បានឱ្យដឹងថា ការជួសជុល អភិរក្សបេតិកភណ្ឌ គឺមិនខុសពីការថែទាំ សុខភាពមនុស្សទេ។ ពេលយើងឈឺ គឺយើងត្រូវទៅពេទ្យដើម្បីឱ្យគ្រូពេទ្យពិនិត្យរោគវិនិច្ឆ័យ។ ក្រោយពីរកឃើញថា ផ្នែក ណាមួយនៃរាងកាយមានបញ្ហា យើងត្រូវរកមូលហេតុរបស់វា។ ដូចគ្នាដែរ វគ្គសិក្សានេះនឹងធ្វើការស្រាវជ្រាវ លើវត្ថុនិង សម្ភារៈ សំខាន់ៗដូចជាមាស ប្រាក់ ឆ្អឹង ឬទង់ដែងជាដើមដែលបានរកឃើញ ហើយធ្វើការវិភាគលើវត្ថុទាំងអស់នោះ។

លោកសាស្ត្រាចារ្យបន្តទៀតថា សម័យនេះ វិទ្យាសាស្ត្រមានសារៈសំខាន់ណាស់សម្រាប់ការងារអភិរក្ស ជួសជុលបេតិកភណ្ឌបុរាណ ហើយក្រុមការងារអភិរក្ស ជួសជុលក្រុមប្រាសាទព្រះពិធូររបស់កូរ៉េ ក៏បាននាំយកសម្ភារៈវិទ្យាសាស្ត្រទាំងនោះមកប្រើប្រាស់សម្រាប់ការងារអភិរក្សជួសជុលនេះដែរ។

«ពួកយើងមកទីនេះ ដើម្បីបង្រៀនអំពីវិធីប្រើប្រាស់និងវិធីសាស្ត្រវិភាគទៅលើសម្ភារៈទាំងនោះតាមរយៈឧបករណ៍Microscope ដោយសង្ឃឹមថាចំណេះដឹងនេះនឹងជួយពង្រឹងសមត្ថភាពរបស់មន្ត្រី-បុគ្គលិកបច្ចេកទេសរបស់អាជ្ញាធរ ជាតិអប្សរា ឱ្យកាន់តែ ល្អប្រសើរឡើងថែមទៀត»។

គួរបញ្ជាក់ដែរថា វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងដោយមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ KCHF និងទីភ្នាក់ងារសម្រាប់កិច្ច សហ ប្រតិបត្តិការអន្តរជាតិកូរ៉េ KOICA ក្នុងគម្រោងជួសជុល អភិរក្សក្រុមប្រាសាទព្រះពិធូរក្នុងតំបន់ឧទ្យានអង្គរ៕

**៦.គេហទំព័រ** CEN

## *១.មន្ត្រី-បុគ្គលិក អាជ្ញាធរ ជាតិអប្សរាទទួលវគ្គបណ្តុះបណ្តាល អំពីវិទ្យាសាស្រ្តពាក់ព័ន្ធនឹងការអភិរក្ស បុរាណដ្ឋាននៅតំបន់អង្គរពីអ្នកជំនាញកូរ៉េ*

(ថ្ងៃទី 25 កក្កដា 2017, ម៉ោង 02:47:PM) ǀ ដោយ: អាជ្ញាធរជាតិអប្សរា(CEN)



សៀមរាបៈ មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាចំនួន១០ នាក់នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យាន អង្គរនិងបុរាណវិទ្យាបង្ការ បានចូលរៀនវគ្គបណ្តុះបណ្តាលស្តីអំពីវិទ្យាសាស្រ្តពាក់ព័ន្ធនឹង ការអភិរក្សបុរាណដ្ឋានក្នុងតំបន់អង្គរ ពីសំណាក់លោកបណ្ឌិត Chung Yongjae សាស្រ្តាចារ្យសាកលវិទ្យាល័យជាតិកូរ៉េនៃបេតិកភណ្ឌវប្បធម៌ នារសៀលថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧។

វគ្គសិក្សានេះមានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២៤ដល់២៨ ខែកក្កដា ឆ្នាំ២០១៧ ដោយផ្តោតទៅលើការសិក្សាអំពីធាតុផ្សំនៃ ថ្មនៅតំបន់អង្គរ ការធ្វើតេស្តថ្ម ការសិក្សាអំពីមូលដ្ឋានវិទ្យាសាស្រ្តសម្រាប់ការងារអភិរក្ស ការពិសោធន៍និងវិភាគដោយ មាស៊ីនMicroscope ការសិក្សាអំពីសិលាវិទ្យា និងការចុះអនុវត្តលើទីតាំងផ្ទាល់។

តាមការបញ្ជាក់ពីលោកសាស្រ្តាចារ្យ Chung Yongjae បានឱ្យដឹងថា ការជួសជុល អភិរក្សបេតិកភណ្ឌ គឺមិនខុសពីការថែទាំ សុខភាពមនុស្សទេ។ ពេលយើងឈឺ គឺយើងត្រូវទៅពេទ្យដើម្បីឱ្យគ្រូពេទ្យពិនិត្យរោគវិនិច្ឆ័យ។ ក្រោយពីរកឃើញថា ផ្នែក ណាមួយនៃរាងកាយមានបញ្ហា យើងត្រូវរកមូលហេតុរបស់វា។ ដូចគ្នាដែរ វគ្គសិក្សានេះនឹងធ្វើការស្រាវជ្រាវ លើវត្ថុនិង សម្ភារៈ សំខាន់ៗដូចជា មាស ប្រាក់ ឆ្អឹង ឬទង់ដែងជាដើមដែលបានរកឃើញ ហើយធ្វើការវិភាគលើវត្ថុទាំងអស់នោះ។

លោកសាស្រ្តាចារ្យបន្តទៀតថា សម័យនេះ វិទ្យាសាស្រ្តមានសារៈសំខាន់ណាស់សម្រាប់ការងារអភិរក្ស ជួសជុលបេតិកភណ្ឌបុរាណ ហើយក្រុមការងារអភិរក្ស ជួសជុលក្រុមប្រាសាទព្រះពិធូររបស់កូរ៉េ ក៏បាននាំយកសម្ភារៈវិទ្យាសាស្រ្តទាំងនោះមកប្រើប្រាស់សម្រាប់ការងារអភិរក្សជួសជុលនេះដែរ។

«ពួកយើងមកទីនេះ ដើម្បីបង្រៀនអំពីវិធីប្រើប្រាស់និងវិធីសាស្រ្តវិភាគទៅលើសម្ភារៈទាំងនោះតាមរយៈឧបករណ៍Microscope ដោយសង្ឃឹមថាចំណេះដឹងនេះនឹងជួយពង្រឹងសមត្ថភាពរបស់មន្ត្រី-បុគ្គលិកបច្ចេកទេសរបស់អាជ្ញាធរ ជាតិអប្សរា ឱ្យកាន់តែ ល្អប្រសើរឡើងថែមទៀត»។

គួរបញ្ជាក់ដែរថា វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងដោយមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ KCHF និងទីភ្នាក់ងារសម្រាប់កិច្ច សហ ប្រតិបត្តិការអន្តរជាតិកូរ៉េ KOICA ក្នុងគម្រោងជួសជុល អភិរក្សក្រុមប្រាសាទព្រះពិធូរក្នុងតំបន់ឧទ្យានអង្គរ៕

## *២.វគ្គបន្ទាយក្បាលចិនជាឧទាហរណ៍មួយនៃពហុជំនឿក្នុងជីវិតខ្មែរ*

(ថ្ងៃទី 25 កក្កដា 2017, ម៉ោង 02:45:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(CEN)



សៀមរាប: គេដឹងហើយថា វត្តអារាមជាទីតាំងនៃជំនឿរបស់ពុទ្ធបរិស័ទអ្នកគោរពព្រះពុទ្ធសាសនា។ ប៉ុន្តែ ដោយសារពុទ្ធបរិស័ទខ្មែរមានជំនឿតដូនតាទាំងផ្នែកជំនឿលើព្រលឹងលើអារក្ខអ្នកតា និងព្រហ្មញ្ញសាសនាផងនោះ ទើបធ្វើឲ្យវត្តភាគច្រើនរបស់ព្រះពុទ្ធសាសនាក៏ក្លាយជាទីតាំងនៃជំនឿដូនតាទាំងអស់នេះដែរ។

ជាក់ស្តែង វត្តប្រាសាទចន្ទរង្សីបន្ទាយចាស់ ឬហៅថា វត្តបន្ទាយក្បាលចិន ស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលស្ថិតនៅក្នុងតំបន់បេតិកភណ្ឌអង្គរដែរនោះ មានទំនៀមទម្លាប់ប្រពៃណីដ៏សម្បូរបែប ត្រូវបានរក្សាទុក និងបន្តគោរពប្រតិបត្តិជាដំណរៀងមក។ គេអាចឃើញជំនឿចម្រុះនេះបានតាមរយៈកិច្ចប្រតិបត្តិរបស់ព្រះសង្ឃនិងពុទ្ធបរិស័ទ ដូចជាពិធីសូត្រមន្តចម្រើនព្រះជន្ម សូត្រមន្តលើករាសីកាត់គ្រោះរំដោះកម្ម ពិធីហៅព្រលឹង ពិធីដេកអង្កររាប ព្រមជាមួយនឹងការតុបតែងគ្រឿងរណ្តាប់ស្លាធម៌ បាយសី ជម ជាដើម។

តាមការសង្កេត នៅរៀងរាល់ថ្ងៃសីល វត្តនេះ មានកិច្ចមួយចំនួន ដែលឧបាសក ឧបាសិកា ចូលមកកាន់វត្ត មិនត្រឹមតែយកចង្ហាន់ មកប្រគេនព្រះសង្ឃប៉ុណ្ណោះទេ គឺពួកគាត់មកដើម្បីឲ្យព្រះសង្ឃកាត់គ្រោះ លើករាសី ឬក៏ធ្វើកិច្ចចម្រើនព្រះជន្ម អាស្រ័យទៅលើការគន់គូរជោគជតារាសីរបស់ពួកគាត់។ ប្រសិនបើ ជោគជតារាសី ចង្អុលបង្ហាញថា ត្រូវចម្រើនព្រះជន្ម ព្រះសង្ឃនឹងរៀបចំសូត្រមន្តចម្រើនព្រះជន្មឲ្យភ្លាមតែម្តង ព្រោះគ្រឿងរណ្តាប់គ្រប់យ៉ាងបានរៀបចំទុករួចស្រេចហើយ។

ជាក់ស្តែង ការរៀបចំគ្រឿងរណ្តាប់ មានច្រើនបែបច្រើនយ៉ាង គឺគ្រឿងរណ្តាប់សម្រាប់ការចម្រើនព្រះជន្ម មានដូចជា អង្ករមួយកញ្ជើសម្រាប់កិច្ចដេកអង្កររាប ព្រមទាំងផ្លែចេកទុំ ផ្លែដូងទុំ, ផ្លែឃ្លោកមួយ និងត្រឡាចមួយដាក់នៅជុំគ្នា, ស្រូវមួយកញ្ជើ ដែលមានដោតស្លឹកចេកខ្ចីមួយធាងខ្លីនៅចំកណ្តាល ដាក់នៅក្បែរអង្ករនោះ។ គ្រឿងរណ្តាប់ដែលធំជាងគេគឺ ចាក់ចេកមានបីថ្នាក់ រំលេចដោយក្បូរក្បាច់រចនាយ៉ាងល្អឆើត ហើយមានគ្រឿងរណ្តាប់នៅពីលើ សុទ្ធតែមួយរយ គឺទៀនមួយរយ ធូបមួយរយ ទង់តូចៗមួយរយ នំមួយរយ លាជមួយរយ ផ្កាមួយរយ ប្រាក់មួយរយ។ នៅពីមុខចាក់ចេកនេះ មានបាយសីប្រាំរួតមួយគូ និងស្លាធម៌មួយគូ ហើយក៏មានពែសម្រាប់បញ្ជូនចោលផងដែរ។ កិច្ចមួយទៀត ត្រូវបានធ្វើរាល់ថ្ងៃ សម្រាប់ឧបាសកឧបាសិកា ដែលយកចង្ហាន់ទៅប្រគេនព្រះសង្ឃ គឺការកាត់គ្រោះលើករាសី។ កិច្ចនេះ មិនតម្រូវឲ្យមានការរៀបចំវែងឆ្ងាយនោះទេ គឺពេលពុទ្ធបរិស័ទយកចង្ហាន់មកប្រគេន ព្រះសង្ឃចាប់ផ្តើមសូត្រមន្តកាត់គ្រោះយ៉ាងសង្ខេប ហើយបន្ទាប់មក ដូនជីពីរបីនាក់ ចូលមកធ្វើកិច្ចហៅព្រលឹងឲ្យ ដោយសំឡេងអឺងកងរំពង លន្លង់លន្លោច។

នេះជាការរួមរស់ជាមួយគ្នាយ៉ាងសុខសាន្តនៃពហុជំនឿរបស់ប្រជាពលរដ្ឋខ្មែរ។ អ្នកស្រុកអង្គរ ត្រូវបានគេជឿថា ជាប្រជាពលរដ្ឋដែលផ្ទុកដោយជំនឿដូនតា ទំនៀមទម្លាប់បុរាណយ៉ាងសំបូរបែប។ នេះក៏ជាការបង្ហាញឲ្យឃើញពីទំនៀមពិធីរបស់ដូនតាខ្មែរ ដែលកំពុតតែបន្តរស់នៅជាមួយនឹងអ្នកស្រុកអង្គរ ហើយធ្វើឲ្យអង្គរជាបេតិកភណ្ឌមានជីវិតរបស់មនុស្សជាតិពិតប្រាកដ៕

## *៣.ជំនឿបែងអារឹស របស់អ្នកស្រុកអង្គរ*

(ថ្ងៃទី 25 កក្កដា 2017, ម៉ោង 02:52:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(CEN)



សៀមរាប: អារឹស ជាជំងឺម្យ៉ាងដែលធ្វើឱ្យកូនកើតហើយមិនគង់ គឺស្លាប់ទៅវិញក្នុងរយៈពេលខ្លី ឬស្លាប់ភ្លាមៗតែម្តង។ ក្មេងដែលស្លាប់ដូច្នេះ អ្នកស្រុកនិយមហៅថា អារឹសម្តាយដើម គឺកូនដែលលួចមកកើតនឹងម្តាយថ្មី (ជាតិនេះ) ដោយមិនប្រាប់ម្តាយដើម (ម្តាយជាតិមុន) ឱ្យដឹង។ ដូច្នេះ ដើម្បីបញ្ចៀសកុំឱ្យម្តាយដើមយកព្រ លឹងកូននោះទៅ (ស្លាប់) គេបានប្រារព្ធពិធីមួយហៅថា «បែងអារឹស»។

បែងអារឹស ជាពិធីអបទេសម្យ៉ាងដែលធ្វើឡើងដើម្បីឧបកិច្ចឱ្យកូនកើតអារឹសរស់នៅមានអាយុយឺនយូរតទៅ។ នេះជាជំនឿមួយដែលនៅសេសសល់ក្នុងតំបន់មួយចំនួននៃឧទ្យានអង្គរ។ អ្នកស្រុកនៅរក្សាជំនឿនិងពិធីនេះតាមភូមិស្រុកខ្លះពេលកូនឈឺ ហើយវានៅតែមានឥទ្ធិពលខ្លាំងក្នុងផ្នត់គំនិតរបស់ពួកគាត់ បើទោះបីពួកគាត់ជឿលើជំនាញគ្រូពេទ្យ ហើយសព្វថ្ងៃវិទ្យាសាស្ត្រផ្នែកសុខាភិបាលមានការរីកចម្រើនខ្លាំងក៏ដោយ ក៏គាត់មិនចោលពិធីនេះដែរ។

តាមការបញ្ជាក់របស់លោកយាយ សយ អាយុ៧៩ឆ្នាំ ជាអ្នករស់នៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាបបានរៀបរាប់ថា គាត់ធ្វើជាអ្នកបែងអារឹសឱ្យគេយូរឆ្នាំមកហើយ ដែលមានរូបស្នងឈ្មោះលោកតាវែង។ លោកយាយបញ្ជាក់ថា ក្មេងដែលមានជំងឺអារឹស គឺដេកកន្ត្រាក់កន្ត្រេង យំមិនឈប់ មិនស៊ី មិនផឹក មិនបៅ ស្គមរីងរៃ។ ភាគច្រើនអារឹសកើតចំពោះក្មេងៗចាប់ពីអាយុ២ខែទៅ៧ឬ៨ខែ ហើយក៏មិនគ្រប់ក្មេងដែរដែលកើតជំងឺនេះ វាក៏កម្រកើតលើក្មេងដែលមានអាយុពី១ឆ្នាំឡើងទៅណាស់។

លោកយាយបន្តទៀត អ្នកស្រុកអង្គរគេជឿជំនឿនេះខ្លាំង ពេលមានក្មេងឈឺក្រៅពីយកទៅពេទ្យហើយ គេតែងអញ្ជើញគាត់ឱ្យទៅបែងអារឹសឱ្យ ហើយភាគច្រើនក៏សមប្រកបផងដែរបន្ទាប់ពីធ្វើពិធីនេះរួច ដោយក្មេងនោះជាសះស្បើយ មានសុខភាពល្អ ហើយអ្នកស្រុកទោះជិតឆ្ងាយដែលមានជំនឿលើការបែងអារឹសនេះ តែងអញ្ជើញលោកយាយឱ្យទៅធ្វើកិច្ចឱ្យជាហូរហែ។ តាមជំនឿតគ្នាមក គេតែងយល់ថា បែងអារឹសជាពិធីមួយដែលធ្វើឡើងឧបកិច្ចដូរកូនគ្នារវាងម្តាយជាតិនេះនិងម្តា

យដើមជាតិមុន ដើម្បីឱ្យក្មេងតូចនោះជាសះស្បើយ។ ការធ្វើពិធីនេះមិនប្រកាន់រដូវកាលខែឆ្នាំទេ តែគេកំណត់យកថ្ងៃព្រហស្បតិ៍ វេលាថ្ងៃត្រង់ ហើយធ្វើនៅផ្លូវបំបែកជា៣ឬជា៤តែប៉ុណ្ណោះឯង។
ចំពោះពិធីនេះមានរៀបចំគ្រឿងរណ្ដាប់ដូចជាៈ ជម៤ ម្លូរ បារី ស្លា ធូប ផ្កា១៣ាន អំបោះដៃ បាយសម្ល មាន់ឆ្អាង មាន់ស្ងោរ កូនង៉ាធ្វើពីដើមចេក ឡានធ្វើពីដើមចេក ត្បាល់ ស្រាស ម្សៅ គ្រឿងក្រអូប។ អ្នកចូលរូបមាននាទីសំខាន់ណាស់នៅក្នុងពិធីនេះ ព្រោះគាត់ជាអ្នកទាក់ទងឆ្លងឆ្លើយនឹងម្ដាយដើមរបស់ក្មេងតូចនោះតាមរយៈការចូលរូប ដើម្បីសួរនាំពីឈ្មោះម្ដាយដើម ឈ្មោះកូន ទីកន្លែង និងបំណងរបស់ម្ដាយនោះ។
ពេលកិច្ចពិធីចាប់ផ្ដើម អ្នកចូលរូបក៏បំពេញនាទីឆ្លើយឆ្លងទាក់ទងនឹងម្ដាយដើមដោយមានមនុស្សម្នាក់ចាំសួរ ឱ្យដឹងថា មកពីណា ចង់បានអ្វី ឈ្មោះអ្វី កូនឈ្មោះអ្វី ឱ្យធ្វើយ៉ាងម៉េចចំពោះក្មេងនោះ និងដើម្បីសុំចរចាទិញកូនពីម្ដាយដើម យកមកឱ្យម្ដាយថ្មីចិញ្ចឹម ដោយដូរឈ្មោះថ្មីឱ្យផង។ ពេលដឹងរឿងរ៉ាវអស់ ក៏មានមនុស្សម្នាក់ត្រូវជាសាច់ញាតិក៏បាន ជាអ្នកភូមិក៏បានអង្គុយយោលអង្រឹងច្រៀងបំពេរលួងលោមកូនង៉ាធ្វើពីដើមចេក ដែលបានឆ្លាក់រូបមានមុខមាត់ភ្នែកច្រមុះ ហើយលាបក្រែមម្សៅយ៉ាងស្អាតឱ្យលង់លក់។
ឯអ្នកផ្សេងទៀត ជួយសែនព្រេនបាយសម្ល ស្រាស ទឹកក្រូច បង្អែមចម្អាបឱ្យម្ដាយដើមនោះផង ព្រមទាំងអារក្ស អ្នកតាដែលថែរក្សាទីភូមិផងឱ្យបានសេពសោយនិងសូមពរសុំជ័យឱ្យកូនចៅសុខសប្បាយ។ ពេលសែនរួច គេក៏យកសំណែនទៅចោល និងមានម្នាក់ចាំធាក់ត្បាល់ឱ្យបែរមុខទៅត្បូង ព្រមទាំងកញ្ចក់កូនង៉ាក្នុងអង្រឹងយកទៅចោលផងដែរ រួមជាមួយមាន់ឆ្អាង ឡានធ្វើពីដើមចេក ដែលគេសន្មត់ជារបស់លេងរបស់ក្មេងនោះ។ ឯអ្នកយោលអង្រឹងនិងច្រៀងបំពេរកូនមុននោះត្រូវយំស្រែកស្ដាយស្រណោះកូនដែលគេកញ្ចក់ទៅបាត់។ ការធ្វើដូច្នេះ គឺដើម្បីឧបកិច្ចជាការដោះដូរកូនគ្នាតាមរយៈរូបជំនួស ដោយឱ្យម្ដាយដើមជាអ្នកយកកូនធ្វើពីដើមចេកទៅវិញ ឯម្ដាយជាតិថ្មីនេះចិញ្ចឹមកូនពិត។
ក្រោយការដោះដូរកូនគ្នារួចហើយ គេក៏បានធ្វើពិធីហៅព្រលឹងឱ្យកូនដែលឈឺនោះយ៉ាងលន្លង់លន្លោង ដើម្បីឱ្យព្រលឹងរបស់គេមកនៅក្នុងរូបក្នុងអង្គ រួមជាមួយការចងអំបោះនៅដៃរបស់ក្មេងតូចឱ្យគេសុខសប្បាយ មានអាយុយឺនយូរ ហើយចាប់ពីពេលនេះទៅ គឺគេត្រូវប្រើឈ្មោះថ្មី។ ម្យ៉ាងទៀតគេក៏បានយកលុយដែលម្ដាយដើមឱ្យជួលចិញ្ចឹមកូននោះមកឱ្យម្ដាយជាតិនេះ ឱ្យពួកគេចិញ្ចឹមកូនឱ្យផង ហើយចងដៃឪពុកម្ដាយក្មេងតូចនោះផងដែរ ដើម្បីឱ្យពួកគេសុខសប្បាយ នៅថែកូនឱ្យបានល្អ៕